**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# សារលិខិត

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានកិត្តិយស នៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត នាឱកាសទិវាជាតិទីក្រុងស្អាត ក្រោមប្រធានបទ «ទីក្រុងស្អាត៖ ទីក្រុងផ្តល់ភាពកក់ក្តៅដល់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរ»

**រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧**

*-សូមថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ*

*-បងប្អូនជនរួមជាតិទាំងអស់ជាទីស្រលាញ់រាប់អាន!*

ថ្ងៃនេះ ខ្ញុំព្រះករុណាខ្ញុំមានសេចក្តីរីករាយជាអនេកដោយបានចូលរួមអបអរសាទរជាមួយបងប្អូនជនរួមជាតិទាំងអស់ក្នុងឱកាសប្រារព្ធទិវាជាតិទីក្រុងស្អាត លើកទី៥ ឆ្នាំ២០១៧ និងពិធីប្រគល់ជ័យលាភីរង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រី សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ លើកទី២ អមជាមួយជ័យលាភីបដិសណ្ឋារកិច្ចល្អសេវាសាធារណៈរបស់ក្រុង/ខណ្ឌ បេក្ខភាពក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាត លើកទី១។ ព្រឹត្តិការណ៍ទាំងអស់នេះពិតជាបានរួមចំណែកបំផុសដល់បងប្អូនជនរួមជាតិទាំងអស់ ពិសេសចំពោះយុវជនកុលបុត្រកុលធីតាខ្មែរឱ្យបន្តជំរុញ និងយកចិត្តទុកដាក់កាន់តែខ្ពស់បន្ថែមទៀត ក្នុងការលើកម្ពស់ការអភិវឌ្ឍបៃតង ការផ្តល់នូវបដិសណ្ឋាកិច្ចល្អដែលជាការចូលរួមចំណែកដល់ការអភិវឌ្ឍវិស័យទេសចរណ៍ និងការរីកចម្រើននៃសង្គមជាតិយើង។

បច្ចុប្បន្នកម្ពុជាមានសុខសន្តិភាព ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់ល្អបរិបូរណ៍ ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធល្អប្រសើរ និងមានការអភិវឌ្ឍលើគ្រប់វិស័យ ហើយមានកំណើនសេដ្ឋកិច្ចខ្ពស់គួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ លើសពីនេះទៀត ក្នុងដំណើរឆ្ពោះទៅមុខ កម្ពុជាត្រូវបន្តខិតខំប្រឹងប្រែងខ្លាំងក្លាបន្ថែមទៀត ដើម្បីទទួលបាននូវភាពរីកចម្រើនសម្រេចបានតាមបំណងប្រាថ្នារបស់ខ្លួនសំដៅបន្តកែលម្អជីវភាព និងការរស់នៅរបស់ប្រជាជន និងការរួមចំណែកថែរក្សាភពផែនដីរបស់យើង សម្រាប់កូនចៅជំនាន់ក្រោយៗទៀត។ ក្នុងនោះ កម្ពុជាត្រូវបន្តយកចិត្តទុកដាក់ខ្ពស់លើការងារសំខាន់ៗជាអាទិ៍៖ ការបន្តកាត់បន្ថយភាពក្រីក្រ ការលើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាជន ការគិតគូរពីចីរភាពនៅតាមបណ្តាទីក្រុង ការឆ្លើយតប និងបញ្ហាបម្រែបម្រួលអាកាសធាតុ កិច្ចការពារ និងអភិរក្សធនធានធម្មជាតិជាដើម។

ក្នុងស្មារតីឆ្លើយតបទៅនឹងការវិវត្តន៍ និងនិន្នាការអភិវឌ្ឍន៍ថ្មីៗនេះ កម្ពុជាត្រូវបន្តយកចិត្តទុកដាក់លើការដាក់ចេញ និងអនុវត្តនូវគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនានា ដោយឈរលើមូលដ្ឋានសំខាន់២ ដែលត្រូវគិតគូរស្របពេលគ្នាគឺ៖ **ការបង្កើនឧត្តមភាពប្រកួតប្រជែង និងការធានានិរន្តរភាពនៃការអភិវឌ្ឍ**។ ឈរលើមូលដ្ឋាននេះ កម្ពុជាក៏បានដាក់ចេញនូវយុទ្ធនាការ **«ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អបដិសណ្ឋារកិច្ចល្អ»** ដែលជាយុទ្ធសាស្ត្រដ៏សមស្របក្នុងការចូលរួមអភិវឌ្ឍវិស័យទេសចរណ៍ជា **មាសបៃតង** និងនាំកម្ពុជាឆ្ពោះទៅរក **ភាពស្អាត និងបៃតង និងប្រកបដោយសុវត្ថិភាពខ្ពស់** ។

ឆ្នាំនេះ ជាឆ្នាំទី៥ ដែលយើងប្រារព្ធធ្វើទិវាជាតិទីក្រុងស្អាត ក្រោមប្រធានបទ **«ទីក្រុងស្អាតៈ ទីក្រុងផ្តល់ភាពកក់ក្តៅដល់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរ»**។ តាមរយៈប្រធានបទនេះ ឆ្លុះបញ្ចាំងយ៉ាងច្បាស់ថាប្រជាពលរដ្ឋគ្រប់រូបតែងប្រាថ្នាចង់រស់នៅក្នុងទីក្រុងដែលមានភាពស្អាត និងបៃតង មានការយកចិត្តទុកដាក់អំពីអនាម័យជុំវិញមជ្ឈដ្ឋានរស់នៅរបស់ពួកគាត់ មានការធានាសន្តិសុខសុវត្ថិភាពពេញលេញ មានការរៀបចំសណ្តាប់ធ្នាប់របៀបរៀបរយល្អ មានការផ្តល់សេវាសាធារណៈប្រកបដោយបដិសណ្ឋារកិច្ចល្អ ពោលគឺទីកន្លែងដែលអាចផ្តល់នូវភាពកក់ក្តៅយ៉ាងពិតប្រាកដសម្រាប់ការរស់នៅរបស់ពួកគាត់។ ដូចគ្នានេះដែរ ភ្ញៀវទេសចរក៏ចង់បានទីក្រុងដែលជាគោលដៅទេសចរណ៍របស់គេជាទីក្រុងដ៏ល្អស្អាតមានការយកចិត្តទុកដាក់អំពីភាពស្អាត និងបៃតង អនាម័យល្អ មានហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់តាមគ្រប់មធ្យោបាយ មានការធានាសន្តិសុខសុវត្ថិភាពពេញលេញ សណ្តាប់ធ្នាប់ល្អ មានការផ្តល់នូវបដិសណ្ឋារកិច្ចល្អ មានសម្បទាផលិតផល និងសេវាទេសចរណ៍ប្រកបដោយគុណភាព។ ទាំងនេះសុទ្ធសឹងជាកត្តាកំណត់ក្នុងការសម្រេចចិត្តជ្រើសរើសគោលដៅសម្រាប់ដំណើរកម្សាន្តរបស់ភ្ញៀវទេសចរនាពេលបច្ចុប្បន្ន។ ក្នុងន័យនេះទីក្រុងដែលគួរឱ្យចង់រស់នៅ និងគួរឱ្យចង់មកទស្សនាកម្សាន្តត្រូវតែជាទីក្រុងបៃតង/ទីក្រុងស្អាត ជាទីក្រុងដែលមានបរិស្ថាន អនាម័យ សណ្តាប់ធ្នាប់ល្អ គួបផ្សំនឹងហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់គ្រប់គ្រាន់ដែលផ្តល់នូវភាពកក់ក្តៅ និងមជ្ឈដ្ឋានរស់នៅល្អប្រសើរដល់ប្រជាជនក្នុងទីក្រុង។

ឆ្លៀតឱកាសនេះ ខ្ញុំព្រះករុណាខ្ញុំសូមឱ្យគ្រប់រាជធានី-ខេត្ត រិះរកគ្រប់វិធីខិតខំជំរុញយន្តការប្រមូលកែច្នៃសំរាម រាប់ទាំងសំរាមជាថង់ប្លាស្ទិក ទាំងអនាម័យសណ្តាប់ធ្នាប់សាធារណៈ ឱ្យបានជាក់លាក់ និងមានប្រសិទ្ធភាព ដោយកំណត់យកឆ្នាំ២០១៨ ជាឆ្នាំនៃការប្រកាសជ័យលាភីទីក្រុងស្អាត លើកទី២ និងជាការប្រកាសលទ្ធផលនៃការប្រឡងប្រណាំងទីក្រុងទេសចរណ៍ស្អាតអាស៊ាន លើកទី ១ ។ សន្តិភាពមិនអាចខ្វះបានសម្រាប់កម្ពុជា ពិភពលោកទាំងមូល **"ប្រជាជនកម្ពុជា ពិភពលោកទាំងមូលក៏ត្រូវការរស់នៅក្នុងសន្តិភាព ក្នុងបរិស្ថានស្អាតល្អ និងបៃតង"**។ ភាពស្អាត និងបៃតង ជានិន្នាការនៃយុគ្គសម័យបច្ចុប្បន្ន និងអនាគតរបស់មនុស្សជាតិ។ សូមចូលរួមទាំងអស់គ្នាដើម្បីកម្ពុជាស្អាត និងបៃតង និងក្លាយជាគោលដៅទេសចរណ៍ដ៏ទាក់ទាញបំផុតក្នុងតំបន់ និងពិភពលោក។

ខ្ញុំព្រះករុណាខ្ញុំក៏សូមអំពាវនាវដល់គ្រប់ក្រសួងស្ថាប័ន រាជធានី-ខេត្ត អាជ្ញាធរគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ វិស័យឯកជន អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍពាក់ព័ន្ធព្រះសង្ឃគ្រប់ព្រះអង្គ លោកគ្រូអ្នកគ្រូ សិស្សានុសិស្ស និស្សិត យុវជន យុវនារី មន្ត្រីរាជការ បុគ្គលិកក្រុមហ៊ុនឯកជន/រោងចក្រ និងបងប្អូនជនរួមជាតិទាំងអស់មេត្តាបន្តផ្តល់ការគាំទ្រ និងចូលរួមអនុវត្តឱ្យបានផុលផុសប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់នូវ**ចលនាប្រឡងប្រណាំងទីក្រុងស្អាត ចលនាប្រឡងប្រណាំងរង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រីសម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ និងចលនាប្រឡងប្រណាំងបដិសណ្ឋារកិច្ចល្អ** ឱ្យបានផុសផុលដើម្បីឱ្យបដិសណ្ឋារកិច្ចល្អរបស់ប្រជាពលរដ្ឋកម្ពុជាក្លាយជា**របៀបវារៈជាតិ**ស្របតាមទស្សនទាន **"បដិសណ្ឋារកិច្ចល្អៈ ជាកាតព្វកិច្ចរបស់យើងទាំងអស់គ្នា"** តាមរយៈការបញ្ចូលគោលគំនិត និងខ្លឹមសារនេះ ទៅក្នុងការងារប្រចាំថ្ងៃរបស់ខ្លួនសំដៅធ្វើឱ្យកម្ពុជាក្លាយជាគោលដៅទេសចរណ៍បៃតងប្រកបដោយគុណភាពចីរភាព និងភាពទាក់ទាញសម្រាប់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ ស័ក្តិសមទៅនឹងកិត្តិនាម **«កម្ពុជាៈព្រះរាជាណាចក្រអច្ឆរិយៈ ផ្តល់ភាពកក់ក្តៅ»** និងដើម្បីត្រៀមទទួលជាម្ចាស់ផ្ទះកីឡា SEA GAME ឆ្នាំ២០២៣ ខាងមុខ។

ខ្ញុំព្រះករុណាខ្ញុំសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថាគ្រប់ភាគីពាក់ព័ន្ធទាំងអស់នឹងបន្តសហការចូលរួមគាំទ្រ ឧបត្ថម្ភ និងអនុវត្តរាល់យុទ្ធនាការនានា ដែលត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាលដើម្បីគាំទ្រដល់ចលនាប្រឡង-ប្រណាំងទីក្រុងស្អាតជាអាទិ៍៖ ចលនាប្រឡងប្រណាំងរង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រីសម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ ចលនាប្រឡងប្រណាំងបដិសណ្ឋារកិច្ចល្អសេវាសាធារណៈរបស់ក្រុង/ខណ្ឌ បេក្ខភាពក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាត ចលនាប្រឡងប្រណាំងបដិសណ្ឋារកិច្ចល្អក្នុងវិស័យទេសចរណ៍ ចលនាប្រឡងប្រណាំងបដិសណ្ឋារកិច្ចល្អរបស់ច្រកទ្វារអន្តរជាតិ យុទ្ធនាការ «ភូមិ-ឃុំមានសុវត្ថិភាព» យុទ្ធនាការ «ប្រយុទ្ធប្រឆាំងគ្រឿងញៀន» និងយុទ្ធនាការ «យុវជននិងទីក្រុងស្អាត» ជាដើម ដើម្បីចូលរួមដល់ការសម្រេចបានជោគជ័យទីក្រុងស្អាត ស្របតាមខ្លឹមសារនៃប្រធានបទ «ទីក្រុងស្អាត៖ ទីក្រុងផ្តល់ភាពកក់ក្តៅដល់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរ» និងសូមជូនពរឱ្យទិវាជាតិទីក្រុងស្អាត និងចលនាប្រឡងប្រណាំងទីក្រុងស្អាត ប្រព្រឹត្តទៅប្រកបដោយជោគជ័យជានិច្ចនិរន្តរ៍។

ជាទីបញ្ចប់ ក្នុងឱកាសអបអរសាទរ «ទិវាជាតិទីក្រុងស្អាត លើកទី ៥ ឆ្នាំ២០១៧» និង «ពិធីប្រគល់ជ័យលាភីរង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រីសម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍ លើកទី ២ អមជាមួយជ័យលាភីបដិសណ្ឋារកិច្ចល្អសេវាសាធារណៈរបស់ក្រុង/ខណ្ឌបេក្ខភាពក្នុងចលនាប្រឡងប្រណាំងទីក្រុងស្អាត លើកទី១» នេះ ខ្ញុំព្រះករុណាខ្ញុំសូមប្រគេនពរ និងជូនពរបងប្អូនជនរួមជាតិទាំងអស់ ជួបតែពុទ្ធិពរទាំង៤ប្រការ គឺ ***អាយុ វណ្ណៈ សុខៈ ពលៈ*** កុំបីឃ្លៀងឃ្លាតឡើយ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៧

**ហ៊ុន សែន**